# ការបញ្ចប់សក្ខីកម្មស្របនឹងពេល ឌុច ធ្វើជាសាក្សីនៅពេលចុងក្រោយ

*ដោយ ម៉ៃ ទឹល សាលីបា*

***ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ឌី សុជាតា*

*តុលាការនៅក្នុងការកាត់ទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅពេលចុងក្រោយក្នុងការប្រឈមមុខទៅនឹងសំនួរពីស្ថាប័នព្រះរាជអាជ្ញានិងមេធាវីការពារក្តីលើបញ្ហាអត្តចរិត្តរបស់គាត់ ។ ស្ថាប័នព្រះរាជអាជ្ញាបានព្យាយាមគូរូប ឌុច ដូចជាបុរសម្នាក់ដែលមានភក្តីភាពចំពោះខ្មែរក្រហមរហូតដល់ពេលផុតរលត់ចុងក្រោយនៃរបបនេះខណៈ ដែលក្រុមមេធាវីការពារក្តីផ្តោតទៅលើការសុំអភ័យទោសរបស់ ឌុច ចំពោះជនរងគ្រោះ និងការយល់ដឹងរបស់គាត់ពីអំពីពិរុទ្ធភាព ។*

*សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញពីចរិតលក្ខណៈរបស់ ឌុច ថាជាបុរសម្នាក់ដែលមានមោទនភាពចំពោះតួនាទីខ្លួននៅគុកទួលស្លែង (មន្ទីរស-២១) ពីព្រោះគាត់ធ្លាប់មានឱកាសធ្វើការជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃរបបខ្មែរក្រហម ។ សហព្រះរាជអាជ្ញាបានអះអាងថា ឌុច ប្រតិបត្តិតាមកាតព្វកិច្ចរបស់គាត់ដោយយកចិត្តទុកដាក់បំផុត និងសប្បាយរីករាយក្រៃលែង ។ សហព្រះរាជអាជ្ញា បានណែនាំថា ការងាររបស់ ឌុច ត្រូវបានជំរុញទឹកចិត្តតាំងពីដំបូងដោយមូលដ្ឋានមួយនិងដោយភាពស្មោះត្រង់ចំពោះរបបខ្មែរក្រហម ។ ឌុច ទទួលខុសត្រូវថា ការងាររបស់គាត់ គឺត្រូវបានធ្វើដោយការជំរុញមិនមែនដោយសារតែភាពស្មោះត្រង់ចំពោះរបបនោះទេ ប៉ុន្តែគាត់ធ្វើដោយភាពភ័យខ្លាចចំពោះសុវត្ថិភាពរគាត់ផ្ទាល់ទៅវិញទេ ។ បន្ទាប់ពីឃើញមនុស្សជាច្រើននៅជិតស្និតនិងគាត់ជាប់ទាក់ទងទៅនឹងសត្រូវគាត់យល់ថា ការចាប់ខ្លួនគាត់គឺមិនអាចជៀសផុតទេ ហើយ ឌុច មានតែរស់នៅដើម្បីបន្តធ្វើឲ្យថ្នាក់លើសប្បាយចិត្តតទៅទៀត ។*

*សហព្រះរាជអាជ្ញាក៏បានអះអាងទៀតថា ឌុច មានភាពស្មោះត្រង់ចំពោះខ្មែរក្រហមរហូតមកដល់ថ្ងៃ ដែលគាត់ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៩៩ ហើយគាត់មិនព្រមទទួលស្គាល់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលទេ រហូតដល់ពេលគាត់បានជួបមេធាវីរបស់គាត់លើកដំបូងនៅក្នុងឆ្នាំ២០០៧ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា តាមការពិត ឌុច មិនបានបោះបង់ចោលបក្សទេបន្ទាប់ពីបរាជ័យថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។ ឌុច ទទួលស្គាល់ថា គាត់ត្រូវបានបូជាខ្លួនជូនបដិវត្តន៍នៅពេលចាប់ផ្តើមនៃរបបខ្មែរក្រហម ប៉ុន្តែគាត់បានអះអាងថា គាត់ចាប់ផ្តើមបាត់បង់ទំនុកចិត្តចំពោះបក្សមុន ពេលដែល*

គាត់បានយល់ដឹងពីចរិត្តនៃបទឧក្រិដ្ឋរបស់បក្ស ។ ឌុច បានពន្យល់ថា គាត់មិនមានលទ្ធភាពក្នុងការរើបំរាស់ដើម្បីចាកចេញទេ ដោយសារតែភាពភ័យខ្លាចពីសុវត្ថិភាពធ្វើឲ្យគាត់ត្រូវតែបន្ត ។

បន្ទាប់មកក្រុមមេធាវីការពារក្តីបានព្យាយាមចង្អុលបង្ហាញថា វិប្បដិសារីរបស់ ឌុច បានធ្វើឡើងដោយភាពស្មោះត្រង់ និងពីការយល់ដឹងនៃសេចក្តីពិរុទ្ធដោយគ្មានលក្ខខ័ណ្ឌ ។ ឌុច បានយល់ព្រមទទួលនូវការពោលអះអាងថា ក្នុងនាមប្រធានមន្ទីរស-២១ គាត់បានប្រព្រឹត្តនូវការសម្លាប់ប្រជាជនកម្ពុជាក្នុងលក្ខណៈដាច់ខាតហើយគ្មានមេត្តា ។ ឌុច បាននិយាយថា គាត់ទទួលខុសត្រូវទាំងផ្នែកច្បាប់ និងផ្នែកអារម្មណ៍ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ និងមិនអាចជំទាស់ទៅនឹងសេចក្តីសំរេចរបស់សាលាជម្រះក្តីបានទេ ។ ឌុច បាននិយាយពាក្យសុំទោសម្តងទៀត ចំពោះជនរងគ្រោះ និងបានសុំឲ្យមានការអភ័យទោសសារជាថ្មីម្តងទៀត ។

នៅពេលរសៀល អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមការងាររបស់ខ្លួនយ៉ាងខិតខំប្រឹងប្រែងក្នុងការទទួលយកសំណើរសម្រាប់ដាក់ឯកសារបន្ថែម ដែលមិនទាន់បានធ្វើមុនពេលដំណើការសាលាដំបូង ។ នៅក្នុងវិធាន៨៧(វិធានភស្តុតាង) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្អែកទៅលើសេចក្តីសំរេចរបស់ខ្លួនលើភស្តុតាងដែលធ្លាប់បានដាក់ និងកម្មវត្ថុក្នុងការពិនិត្យ ។ ភស្តុតាង គឺជាផ្នែកមួយនៃសំនុំរឿង ប៉ុន្តែវាមិនធ្លាប់បានយោងនៅក្នុងអំឡុងពេលកាត់សេចក្តីទេ គឺគ្រាន់តែដាក់បង្ហាញនៅចំពោះមុខភាគី ។

បញ្ហាចម្បងនៃរឿងវិវាទរវាងស្ថាប័នព្រះរាជអាជ្ញា និងមេធាវីការពារក្តី បានលើកឡើងពីសំណើររបស់ស្ថាប័នសហព្រះរាជអាជ្ញា ក្នុងការស្នើសុំឲ្យដាក់នូវសេចក្តីពន្យល់ពីចម្លើយសារភាពនៅមន្ទីរស-២១ ដែលមិនបានយោងនៅអំឡុងពេលកាត់សេចក្តី ។ កម្មវត្ថុចម្បងរបស់មេធាវីការពារក្តី គឺមិនមានឱកាសក្នុងការពិនិត្យចម្លើយសារភាពទាំងនេះទេ ។ មេធាវីការពារក្តីកត់សម្គាល់ថា វាបានបង្ហាញភិនភាគមិនត្រឹមត្រូវជាច្រើននៅក្នុងការបកប្រែមួយចំនួននិងសេចក្តីពន្យល់ ដែលត្រូវបានយោងនៅក្នុងពេលកាត់សេចក្តី ។ តាមរយៈមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឌុច មានលទ្ធភាពក្នុងការផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូងនូវបរិបទនៃសាវតារដ៏សំខាន់ យោងការសារភាព ដោយសារតែ ឌុច បានធ្វើសេចក្តីពន្យល់ផ្ទាល់ខ្លួនជាច្រើនក្នុងចំនោមចម្លើយសារភាពទាំងនោះ ។ ដូច្នេះ មេធាវីអះអាងថា ការអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងមានជំនឿទៅលើសេចក្តីពន្យល់អំពីចម្លើយសារភាព ដែលមិនបានពិនិត្យដោយមេធាវីការពារក្តី គឺធ្វើឲ្យខូចប្រយោជន៍ដល់ជនជាប់ចោទ ។

អង្គជំនុំជម្រះសាលាដំបូង នឹងប្រជុំដោយសង្ខេបនៅពេលព្រឹកស្អែក ដើម្បីទទួលសំណើចុងក្រោយសម្រាប់ការដាក់ជូននូវឯកសារបន្ថែម ដែលចំនុចខ្លះត្រូវបានរំពឹងទុកថា នឹងពន្យារពេលរហូតដល់សេចក្តីសំអាងចុងក្រោយនៅថ្ងៃទី២៣ ខែវិច្ឆិកា ។